www.khmerpostusa.com
សារព័ត៌មាន ខ្មែរផុស្ដ៍ ស.រ.អា
# KhmerPost USA


Soben Pin
Co-Founder & Publisher

Free Copies
Vol. 13. Issue #291
March 23, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

ពិភពលោកប្រយុទ្ធប្រឆាំងនឹងជំងឺអាសន្នរោគថ្មី "កូរ៉ូណាវីរុស"
សូមអាននៅទំព័រទី ០៣



ការណែនាំអំពីផលិតផលកម្ចាត់មេរោគ
សូមអាននៅទំព័រទី ០៩



ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ...
សូមអាននៅទំព័រទី ១៥



សង្គ្រាមរួម
សូមអាននៅទំព័រទី ១១



# Fast Facts about Corona Virus

Khmer Post USA Biweekly Report | By Soben Pin Read Page 02

# ក្រសួងសុខាភិបាលរកឃើញអ្នកឆ្លងជំងឺ Covid-19 ចំនួន៣១នាក់ទៀត ដែលចំនួនអ្នកឆ្លងសរុបកើនដល់៨៤នាក់



ភ្នំពេញៈ ក្រសួងសុខាភិបាលបានប្រកាសឱ្យដឹងថា ខ្លួនបានរកឃើញអ្នកឆ្លងជំងឺកូវីដ១៩ (COVID-19) ថ្មីចំនួន៣១បន្ថែមទៀត នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០នេះ ដែលធ្វើឱ្យចំនួនអ្នកឆ្លងសរុបនៅក្នុងប្រទេសកម្ពុជា បានកើនដល់ ៨៤នាក់ហើយ ។នេះបើតាមសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាលបានប្រកាស ។

បើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា ករណីថ្មីនេះភាគច្រើន ត្រូវបានរកឃើញនៅសណ្ឋាគារមួយកន្លែងជាទីដែលជនជាតិបារាំង២នាក់ឆ្លងជំងឺកូវីដ១៩ស្នាក់នៅ បន្ទាប់ពីក្រសួងសុខាភិបាល បានយកសំណាករបស់ពួកគេទៅពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រ ។

ក្នុងចំណោមអ្នកឆ្លងថ្មី ៣១នាក់នេះ មានជនជាតិបារាំងចំនួន២៩នាក់ និងជនជាតិខ្មែរចំនួន២នាក់ ។ ជនជាតិបារាំងទាំង២៩នាក់

**តទៅទំព័រទី០៥**



**មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL**

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្លូវច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

*Excellent Service Since 1987*
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# Fast Facts about Corona Virus

## Khmer Post USA Biweekly Report

**By Soben Pin**

As we are all trying to adjust to the effects of the Corona Virus, I would like to wish you and your families health and safety. I want to let our readers know that we're committed to continue to deliver news to you and your families during this critical time. We're printing today in print and on our website at www.khmerpostusa.com

In this issue of Khmer Post USA, we focus on the nature of the Corona Virus, how it spreads, how you can protect yourself, schools and business closures and tips on how to stay positive for your mental health during this prolonged social isolation.

Since our last edition two weeks ago, there have been many updates of Covid-19 that has affected on our everyday life. Two weeks ago, kids were still having normal days, going to school and parents were able to go to work. Since last Monday, millions of children across the country are no longer able to school and families are urged to stay at home. A severe measure taken by our government as President Donald Trump declared a national emergency.

At first I thought, as many people did, that maybe it was social media that made the fear of the corona virus






worse. I didn't worry about it. As I followed the alarming increase in the number of cases within days, it became clear that this was a pandemic.

**Here what I've gathered so far:**

**Travel Ban**

President Donald Trump banned over a dozen countries from traveling into the United States. First was China on January 31, Iran on February 29, then the European countries on March 11. Southeast Asian countries were also closing the borders from Cambodia to Vietnam and Thailand. The U.S. Embassy posted a travel advisory for Cambodia, Thailand and Vietnam as category number 4, which means no travel. In Cambodia the number of reported Corona virus is 87 people are infected as of Monday March 23, 2020.

**Number of Deaths**

Latest news as of March 23, more than 30,000 cases have been confirmed positive with corona virus in the the United States and 428 patients have died from the virus. In Massachusetts, there are 777 people infected by the virus and 9 people have died. Half of the population infected by the corona virus in Massachusetts are 49 years and younger. The rapid number of infected individuals have gone up nearly 30% since the day before. It is advised that the families and children are to stay inside their homes to help slow down the spread of the corona virus.

**Corona Virus Relief Bill**

The sweeping $1 trillion legislation **Read Page 08**



# ពិភពលោកប្រយុទ្ធនឹងជម្ងឺអាសន្នរោគថ្មី“កូរ៉ូណាវ៉ាយរ៉ុស”

ដោយ ពិន សំខុន

ភាពភ័យអាសន្នស្លន់ស្លោរបស់ក្រុមគ្រួសារ អាមេរិកាំង-ខ្មែរ នាសប្តាហ៍មុននឹងសប្តាហ៍នេះ នៅពេលលឺថា ជម្ងឺដ៏កាចសាហាវមួយ ឈ្មោះ "កូរ៉ូណាវ៉ាយរ៉ុស"ឬ"កូវិត១៩" កំពុងតែរាតត្បាត យ៉ាងឆាប់រហ័សក្នុងពិភពលោកយើងនោះ... ប្រជាពលរដ្ឋអាមេរិកាំង រួមទាំងខ្មែរយើងផង បានទៅទិញម្ហូបអាហារ អង្ករទឹកត្រីសាច់ សម្ភារៈ ប្រើប្រាស់ មានអាល់កុល ក្រដាស់ជូតដៃ ក្រដាស់ បង្គន់...យ៉ាងដណ្តើមគ្នា ដើម្បីស្តុកទុករើអស់ពី ក្នុងហាងទំនិញ បង្ការក្រែងមានអាសន្ន អត់ម្ហូប អាហារនឹងរបស់ប្រើទាំងនោះ ។

រដ្ឋាភិបាលអាមេរិកាំងបានចេញបទបញ្ជា ក្នុងតំបន់ផងក្នុងប្រទេសផងដើម្បីទប់ស្កាត់ការ ឆ្លងរាលដាលរបស់ជម្ងឺ"កូរ៉ូណា"នេះ ដោយមិន ឱ្យធ្វើដំណើរមិនថា ឆ្ងាយ ឬជិត, មិនឱ្យមានការ រួមប្រជុំលើសពី១០នាក់, មិនឱ្យបើកសាលា រៀន រោងចក្រខ្លះត្រូវបិទទ្វារ មិនឱ្យធ្វើការជុំគ្នា, មានកិច្ចការមួយចំនួនម្ចាស់ហាងតម្រូវឱ្យធ្វើការ តាមកុំព្យូទ័រពីផ្ទះក៏បាន ។

ភោជនីយដ្ឋាននៅឡូវែលជាច្រើន ក៏ដូចជា ហាងនៅទូទាំងប្រទេសដែរ ត្រូវបានបិទទ្វារ ពី២សប្តាហ៍ទៅមួយខែ ខ្លះបិទដោយ ចិត្តឯង ដូច ជាភោជនីយដ្ឋាន"ភ្នំពេញ"នឹងបិទទ្វារ១ខែតែ ម្តង។ រីឯភោជនីយដ្ឋាន"សាំភ្លីខ្មែរ" គេបើក សម្រាប់តែទិញយកទៅក្រៅ ឬក៏យកទៅឱ្យ ដល់ផ្ទះតែប៉ុណ្ណោះ, ភោជនីយដ្ឋានឯទៀតៗដូច ជាភោជនីយដ្ឋាន"កូឡាបក្រហម" ឬហាងដទៃ ឯទៀត ក៏នៅក្នុងសភាពដូចគ្នា ។

មួយអាទិត្យមកហើយនេះ មិនមានឡាន បើកឆ្វាត់ឆ្វែងនៅតាមផ្លូវ ដូចពីមុនទេ កិច្ចជួប ជុំសម្រាប់ប្រកួតកីឡា ឬក៏រោងកុន រោងល្ខោន ក៏ត្រូវបិទអស់ ដោយគេចៀសវៀងការជួបជុំនាំ ឱ្យឆ្លងជម្ងឺ"កូវិដ១៩"។ ពិធីបុណ្យសពខ្មែរ ដែលជាវប្បធម៌ដ៏សំខាន់របស់ខ្មែរយើង ក៏ត្រូវ បង្រួញមកត្រឹមតែឱ្យមានក្រុមគ្រួសារមិនលើស ពី២៥នាក់ទេ ហើយគេឱ្យដង្ហែរចេញពីកន្លែង ដំកល់សពសំដៅទៅទីបច្ឆា ដើម្បីបូជាសពតែ ម្តង ដោយមិនចាំបាច់ សូត្រមន្ត ឬក៏មិនឱ្យទៅ ធ្វើបុណ្យឯវត្តអារាមនោះទេ។

ភាពស្ងាត់ជ្រងំ នៅតាមទីក្រុងតូចឬធំ គឺ ជាវិធានការដ៏ក្តៅដៃ ដែលរដ្ឋបាលលោកប្រធានា ធិបតី ឌុណល ត្រម បានប្តេជ្ញាចិត្តថា ត្រូវតែទប់ ទល់ឱ្យបាន ដូចគ្នានឹងចិត្តរបស់សមាជិសភាខាង គណបក្សប្រជាធិបតេយ្យ ដែលបានតម្លើងថវិការ ផ្តល់ឱ្យរដ្ឋបាល ត្រាំ លើសពីសំណើរទៅទៀត ។



លោក ចាន់ ទូច C.N.P

គេប្រាកដជាមិនចង់ឃើញគំរូនៃអាសន្នរោគឆ្លង នាឆ្នាំ១៩១៨ ដោយមេរោគ H1N1 បានរាល ដាលយ៉ាងទូលំទូលាយបណ្តាលឱ្យស្លាប់មនុស្ស ក្នុងពិភពលោកប្រមាណ៥០លាននាក់ ។

មានតែហាងលក់ឧបភោគបរិភោគ Grocery អាស៊ីនៅឡូវែល នឹងឱសថស្ថានទេដែល នៅបើកទ្វារ នឹងហាងដែលអាច នៅបើកលក់ បាន តែមុខអីវ៉ាន់ចាំបាច់តែប៉ុណ្ណោះ...ហាងខ្មែរ ជាច្រើន បានត្រូវភ្ញៀវសំរុកទិញ ហើយនិយាយ ថា បណ្តាលឱ្យទំនិញចាំបាច់ជាច្រើនមុខបានឡើង ថ្លៃ ដូចជាអង្ករ ទឹកត្រី ម្ហូបកំប៉ុង..., វាផ្ទុយគ្នា នឹងហាងធំនៃពួកសាសន៏ស ទឹក ភេសជ្ជៈ ម្ហូប កំប៉ុង ក្រដាស់... បែរជាចុះថោកទៅវិញ! ។






មណ្ឌលសុខភាពរាប់ទាំងមន្ទីពេទ្យនៅ ត្រៀមខ្លួនទទួលអ្នកជម្ងឺដែលចាំបាច់ ច្រើនព្យា បាលតាមទូរស័ព្ទ តែពិនិត្យកំដៅនឹងតេស្ត អាការៈរោគ កូវិដ១៩ យ៉ាងប្រុងប្រយ័ត្នចំពោះ ការឆ្លងដោយការលាងដៃ ឬការសំអាតកន្លែង ធ្វើការរៀងរាល់ម៉ោង។

លោក ឆាន ទូច គ្រូពេទ្យនៅមណ្ឌលសុខភាពឡូវែល បានផ្តល់ការណែនាំថា ជម្ងឺដែល កើតពីមេរោគ កូវិត១៩ វាមានពេលពី២-១៤ ថ្ងៃ ដើម្បីឆ្លងធ្វើឱ្យយើងឈឺ (Incubation period) ហើយបន្ទាប់ពីពេលនោះទៅ ទើបមានរោគសញ្ញា ដូចជាក្តៅខ្លួន ក្អក ហៀរសំបោរ ដែលបញ្ជាក់ថា មានវត្តមាន កូរ៉ូណាវ៉ាយរ៉ុស នៅក្នុងខ្លួនយើង ហើយ...ប៉ុន្តែមេរោគ កូវីត១៩ ផ្តើមពង្រាយ រួចឆ្លងពីម្នាក់ទៅម្នាក់ទៀត តាមការ ក្អក កណ្តាស បង្ហោះមេរោគ កូវីត១៩ រាប់ពាន់ម៉ឺន តាមខ្យល់ បន្តទៅអ្នកដ៏ទៃតាំងពី២-ទៅ១៤ថ្ងៃមកម្ល៉េះ ដែរ... ដូច្នេះហើយ យើងត្រូវឧស្សាហ៍ទៅលាង ដៃ ពីព្រោះយើងបានទៅកាន់បង្កាន់ដៃ ពេលឡើង ជណ្តើរ ពេលកាន់តុកៅអី ពេលទៅអង្គុយ... ដែលមេរោគបានទៅទុំនៅទីនោះ... ដៃជាកន្លែង សម្រាប់ចម្លងជម្ងឺច្រើនជាងគេបំផុត ដូច្នេះចូរ សំអាតវាឱ្យញឹកញាប់ ។

លោក ឆាន ទូច បន្តរថា នៅ"មជ្ឈមណ្ឌល សុខភាពឡូវែល"របស់លោក នៅបើកទ្វារពី ម៉ោង៩ព្រឹក ដល់ម៉ោង៥ល្ងាចដូចធម្មតា ប៉ុន្តែ មិនមានទទួលអ្នកដែលមកពិនិត្យជម្ងឺ មិនបាន ប្រាប់ជាមុននោះទេ ភ្ញៀវទាំងនោះត្រូវតែទទួល ការត្រួតពិនិត្យ ឆែករកកូវិត១៩ ជាមុនសិន។

មេរោគនោះ វានឹងចូលតាមច្រមុះ ទៅធ្វើឱ្យ រលាកទងសួត រួចឱ្យរលាលសួត លែងទទួល ខ្យល់"អុកស៊ីហ្សែន"បាន ក៏សម្លាប់មនុស្សបាន ដោយសរីរាង្គខូចខាត ដោយគ្មានខ្យល់"អុកស៊ី ហ្សែន"ដកដង្ហើម ។

សភាពការក្នុងប្រទេសរបៀបនេះ វាធ្វើ ឱ្យការងារគាំងដំណើរ សេដ្ឋកិច្ចដាំក្បាលចុះយ៉ាង លឿន មិនថាធានាគារឬរោងចក្រទេ។ រដ្ឋាភិបាល បានចេញសេចក្តីប្រកាស កាលពីថ្ងៃពុធ ទី ផ្តល់ ឱវាទដល់ពលរដ្ឋ កូនសិស្ស នៅផ្ទះឱ្យបានច្រើន ដើម្បីផ្តាច់ទំនាក់ទំនងមនុស្ស ដែលមេរោគ អាច នឹងឆ្លងពីម្នាក់ទៅម្នាក់ទៀតបាន ។ រដ្ឋាភិបាល អាមេរិកាំងបានសន្យាផ្តល់សម្បទាន ដល់ពលរដ្ឋ ម្នាក់ៗចំនួន១០០០ដុល្លាក្នុង១នាក់ នឹងក្មេង ម្នាក់ចំនួន៥០០ដុល្លារ ។ បើនៅ៣ខែខាងមុខ កូវិដ១៩ មិនបានចុះថយទេនោះ ការបិទទ្វារ អាគារសាធារណៈ និងឯកជន នឹងត្រូវបន្តទៅ ទៀត ពេលនោះរដ្ឋនឹងផ្តល់សម្បទានបន្ថែម ចំនួន១០០០ដុល្លារ សម្រាប់ពលរដ្ឋ ម្នាក់ៗ ថែម ទៀត ដើម្បីកាំទ្រដល់គ្រួសារអាមេរិកាំងម្តង ទៀត ។

ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

# មេធាវី ល្វីសហាស្តែល ពន្យល់ពីផ្លូវច្បាប់ស្តីការនិរទ្ទេស


មេធាវី ល្វីស ហាស្តែល

កាលពីមុន ខ្ញុំធ្លាប់បានសរសេររួមមក ហើយនូវអត្ថបទទាក់ទងនឹងត្រូវធ្វើយ៉ាងណាដើម្បីបញ្ជាស់ពីដីការនិរទេសទៅប្រទេសកំណើតវិញ តាមរយៈការតតាំងតាមផ្លូវតុលាការថា តើបទល្មើសដែលបង្កឱ្យមានការចេញនូវដីការនិរទេសនៅតែបង្ហាញនូវហេតុផលត្រឹមត្រូវស្របតាមដីការនិរទេស ឬក៏អត់នោះ។ សំណុំរឿងទាំងនេះ គឺវាគួរឱ្យចាប់អារម្មណ៏ដោយសារតែវាជារឿងទាក់ទងនឹងការពិភាក្សាតទល់ផ្នែកច្បាប់ ហើយអង្គហេតុនៃរឿងក្តីទាំងនេះ គឺស្ទើរតែមិនជាប់ទាក់ទងនឹងគ្នាអ្វីបន្តិចសោះឡើយ។ ទោះជាយ៉ាងណាក៏ដោយមិនមានមនុស្សជាច្រើននាក់ទេ នឹងទទួលបានដីការនិរទេសនេះ វាគឺអាស្រ័យទៅ លើបទល្មើសដែលប្រព្រឹត្តនោះ លែងជួយពួកគេបាន។ នៅក្នុងសហគមន៏របស់យើងវិធីជាគោលការណ៏ដើម្បីជាសវែងដីការបណ្តេញចេញពីប្រទេសលើកចុងក្រោយ (Final Order of Removal) គឺត្រូវតែងតាំងស្របតាមរដ្ឋធម្មនុញ្ញនៃការផ្តន្ទាទោសដើមដំបូង (Original conviction) ចំពោះជំនួយដែលគ្មានប្រសិទ្ធភាពរបស់តំណាងមេធាវីចុងចោទ។

នៅខែមិនា ឆ្នាំ២០២០ តុលាការកំពូលរបស់អាមេរិកបានកាត់ក្តីសំណុំរឿងដែលមានឈ្មោះថា Padilla v. Ky ដែលបានដាក់ក៏រិតលើ អ្នកច្បាប់ឱ្យបំពេញកាតព្វកិច្ចក្នុងការជូនដំណឹងឱ្យបានពេញលេញដល់ចុងចោទអំពីផលវិបាកនៃការធ្វើនិរទេស (Immigration Consequence) នៃការសាភាពទទួលទោស។ រដ្ឋម៉ាសាជូសេតបានពង្រីកការទាមទារឱ្យមានការជូនដំណឹងនេះ ដើម្បីបន្ថែមការផ្តល់យោបល់ដល់ចុងចោទពីផលវិបាកនៃការធ្វើអន្តោប្រវេសន៏នៅពេលកាត់ក្តី ហើយបានធ្វើឱ្យការទាមទារនេះ មានប្រតិសកម្ម រឺធាក់ថយក្រោយ (អ្នចច្បាប់ត្រូវអនុវត្តច្បាប់ដែលចូលជាធរមានក្រោយបទល្មើសកើតឡើង) ចំពោះ "បទល្មើសមានស្ថានទម្ងន់ទោស ឬទោសព្រហ្មទណ្ឌ" (aggravated felonies) ដែលចុះនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩១៧ ដោយប្រែក្លាយទៅជាការទោសបែបផ្តាច់ជីវិតដល់អ្នកដែលអន្តោប្រវេសរស់នៅសហរដ្ឋអាមេរិកមិនទាន់មានសញ្ជាតិ។ មេត្រាប្រតិសកម្មនេះ គឺវាសំណាស់ដោយសារដីការភាគច្រើនក្នុងគោលបំណងធ្វើបញ្ជូនអតីតៈជនភាសខ្លួនខ្មែរ ដែលជាប់ពាក់ព័ន្ធនឹងបទល្មើព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តក្នុងកំឡុងថ្ងៃទី១ ខែមេសា ឆ្នាំ ១៩៩៧ ដល់ខែមិនា ឆ្នាំ២០១០ ទៅកាន់ប្រទេសកម្ពុជាវិញ។ ក្នុងកំឡុងពេលនេះ អ្នកច្បាប់មិនសូវអនុវត្តមានប្រសិទ្ធភាពណាស់ណានោះទេ ក្នុងការផ្តល់មតិយោបល់ ឬផ្តល់ព័តិមានដល់អតិថិជនរបស់ពួកគេអំពីព័តិមានស្តីពីផលវិបាកនៃការបណ្តេញចេញពីប្រទេស ហើយអ្នកច្បាប់ជាទូទៅមិនបានយល់ថាបទល្មើព្រហ្មទណ្ឌជាច្រើនដែលមិនទំនងជាធ្ងន់ធ្ងរ ប៉ុន្តែបែទៅជាមានទោសព្រហ្មទណ្ឌទៅវិញ។ ជាការពិតណាស់មនុស្សភាគច្រើនដែលខ្ញុំបានធ្វើជាតំណាងចំពោះសំណុំរឿងក្តី Padilla v. Ky មិនដែរចំណាយពេលមួយថ្ងៃនៅក្នុងគុកនោះទេចំពោះបទល្មើសពីមុនដែលមិនទាន់ត្រូវបានចាត់ជាទោសព្រហ្មទណ្ឌ ហើយមិនទាន់ស្ថិតនៅក្រោមការធ្វើនិរទេសដោយស្វ័យប្រវត្តិនោះដែរ។

បើទោះបីជាមនុស្សភាគច្រើនមិនបានទទួលដីការព្រមានពីការធ្វើអន្តោរប្រវេសជាក់លាក់និងត្រឹមត្រូវពីមេធាវីរបស់ពួកគេក្នុងកំឡុងពេលវេលានេះយ៉ាងណាក៏ដោយ តែវាមិនបានចែង ថាដីការព្រមានដែលមិនបានចេញឱ្យនោះ គឺវាមិនគ្រប់គ្រាន់នោះទេ។ វាក៏ជាការចាំបាច់ណាស់ ក្នុងការបង្ហាញថា ការទទួលបានដីការព្រមាននេះនឹងអាចធ្វើឱ្យមានភាពខុសគ្នាបាន។ មានវិធីសំខាន់បីក្នុងការដែលធ្វើឱ្យមានភាពខុសគ្នានេះ។ ទីមួយគឺថា លិខិតព្រមាននឹងបានផ្តល់នូវហេតុផលមួយក្នុងការជំទាស់នឹងការសាភាពហើយ និងការជំនុំជម្រះសំណុំរឿងនេះ ដោយសារតែមានអំណោះអំណាងការពារដ៏ជាក់លាក់មួយ។ វិធីម៉្យាងទៀត គឺត្រូវបង្ហាញថា វានឹងអាចធ្វើទៅបានក្នុងការចចារទៅលើការសាភាព ដែលមិនបានបង្កើតឱ្យមានផលវិបាកនៃការបណ្តេញចេញពីប្រទេសដែលប្រកបដោយគ្រោះថ្នាក់បែបនេះនោះទេ។ រឿងក្តីមួយក្នុងចំណោមសំណុំរឿងដែលងាយស្រួលបំផុតដែលខ្ញុំធ្លាប់បានចូលរួម គឺបុរសម្នាក់ដែលត្រូវបានបញ្ជូនទៅកាន់តុលាការ ហើយបានរកឃើញថា មានទោសពីបទការបៀតបៀន និងការបំពានលើរូបកាយកាលពីឆ្នាំកន្លងទៅ។ គាត់ត្រូវបានគេកាត់សម្រេចព្យរទោសរយៈពេល ៣៦៥ ថ្ងៃ ដែលត្រូវបានគេគិតថា ទោសរបស់គាត់ជាបទល្មើសព្រហ្ម ទណ្ឌនៅក្នុងពេលនោះ ហើយជាលទ្ធផលគាត់ត្រូវបានគេនិរទេសចេញពីអាមេរិកដោយស្វ័យប្រវត្តិ។ ប្រសិនបើមេធាវីបានសួរពីឱ្យបានច្បាស់លាស់នោះ វាគ្មានការសង្ស័យទេអ្វីនៅទេ ដែលចៅក្រមបានសម្រេចព្យរទោសរយៈពេល៣៦៥ថ្ងៃនោះ។ នៅក្នុងច្បាប់ស្តីពីការនិរទេស គឺវាពុំមានចែងអ្វីទាំងអស់។ វិធីទីបី គឺត្រូវបង្ហាញពីកាលៈទេសៈពិសេសបែបនេះដែលបានកើតមាន ឡើងដោយជនជាប់ចោទនឹងសុខចិត្តឡើងទៅតុលាការដើម្បីកាត់ក្តី បើទោះបីជាវាអាចនឹងមិនសមហេតុផលក្នុងការកាត់ក្តីក៏ដោយព្រោះសង្ឃឹមថា ការទៅនេះនឹងអាចចៀសវាងការនិរទេសបាន។

អាស្រ័យហេតុនេះ វាគឺអាចទៅរួចដែលថាមនុស្សម្នាក់ដែលត្រូវបានគេផ្តន្ទាទោសពីបទឧក្រិដ្ឋមានស្ថានទំងន់ទោស(ព្រហ្មទណ្ឌ)ជាក់ស្តែង ឬបទឧក្រិដ្ឋផ្សេងទៀតដែលនាំឱ្យមានការធ្វើនិរទេសទៅកាន់ប្រទេសកំណើតវិញ អាចនឹងត្រូវបានគេចាត់សំណុំរឿងនេះជាមោឃៈបានដោយផ្អែកលើមូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញដែលចែងពីជំនួយដែលគ្មានប្រសិទ្ធភាពរបស់តំណាងមេធាវីចុងចោទ។ ខ្ញុំបានទទួលរឿងក្តីមួយដែលកូនក្តីរបស់ខ្ញុំត្រូវបានផ្តន្ទាទោសពីរករណីដាច់ដោយឡែកពីគ្នា ដែលធ្វើឱ្យគាត់អាចត្រូវនិរទេសបាន។ ទោសទីមួយ គឺជាបទឧក្រិដ្ឋមានស្ថានទំងន់ទោស (ការប៉ុនប៉ងធ្វើមនុស្សឃាត) និងទោសមួយទៀតគឺជាករណីកាន់កាប់អាវុធ ហើយខ្ញុំអាចធ្វើឱ្យទោសទាំងពីរករណីនេះទៅជាមោឃៈបានដោយឈរលើមូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញដែលចែងពីជំនួយគ្មានប្រសិទ្ធភាពរបស់មេធាវីចុងចោទនេះ។ ខណៈពេលដែលមនុស្សគ្រប់គ្នាមិនមានលទ្ធភាពក្នុងនាំនូវសំណើរសំណុំរឿង Padilla រឺក៏នាំសូម្បីតែសំណើរដែលមានលក្ខណៈប្រគួតប្រជែងមួយ មនុស្សគ្រប់គ្នា ដែលមានដីការនៃការបណ្តេញចេញដោយសារតែការផ្តន្ទាទោសព្រហ្មទណ្ឌនេះ យ៉ាងហោចណាស់គួរតែត្រូវស៊ើបអង្កេតពីលទ្ធភាពដែលអាចធ្វើទៅបានចំពោះការប្រើប្រាស់មូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញដែលចែងពីជំនួយគ្មានប្រសិទ្ធភាពរបស់មេធាវីចុងចោទនេះ។





មណ្ឌលពិនិត្យសុខភាពលីន

Lynn Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

អាស័យដ្ឋាន

280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755

ទទួលយកម៉ាសហេល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ

Family Medicine

សុខភាពផ្លូវចិត្ត

Behavioral Health

We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

តមកពីទំព័រទី ០១

# ក្រសួងសុខាភិបាលរកឃើញអ្នកឆ្លង...

ដែលឆ្លងនោះបានទៅស្នាក់នៅខេត្តព្រះសីហនុ។ ចំណែកជនជាតិខ្មែរ២នាក់ដែលឆ្លងនោះ គឺជាអ្នកមគ្គុទេសទេសចរឱ្យក្រុមបារាំងនោះ។

បើតាមការប្រកាសរបស់ក្រសួងសុខាភិបាល, បច្ចុប្បន្នជនជាតិបារាំង២៩នាក់ និងជនជាតិខ្មែរ២នាក់ ដែលផ្ទុកមេរោគកូវីដ១៩ត្រូវបានដាក់ព្យាបាលឱ្យនៅដាច់ដោយឡែក តាមបន្ទប់នៅក្នុងសណ្ឋាគារមួយដោយមានការបិទជាបណ្តោះអាសន្នមិនឱ្យមានការចេញចូលដោយគ្មានភារកិច្ចឡើយ។

គិតត្រឹមម៉ោង៨:០០ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានកូវីដ១៩ នៅកម្ពុជាមានចំនួនសរុប៨៤នាក់ហើយ (ស្រី២១នាក់ ប្រុស៦៣នាក់ ដែលក្នុងនោះមានចិន១នាក់ (នៅ






ខេត្តព្រះសីហនុបានជាសះស្បើយ) អង់គ្លេស៣នាក់ (ក្នុងនោះមាន១នាក់) បានជាសះស្បើយ ហើយ) កាណាដា១នាក់ បែលហ្ស៊ិក១នាក់ បារាំង៣៣នាក់ (ក្នុងនោះ-មានកូនប្រុសបង្កើតអាយុ ៤ខែ) ម៉ាឡេស៊ី១២នាក់ និងខ្មែរ៣៣ នាក់។

ក្រសួងសុខាភិបាលបានបញ្ជាក់ថា ក្រុមការងាររបស់ខ្លួន កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីបន្តទៀត ហើយនឹងបន្តជម្រាបជូនប្រជាពលរដ្ឋ ប្រសិនបើមានករណីវិជ្ជមានកូវីដ១៩ថ្មីណាផ្សេងទៀត។

អ្នកដែលត្រូវបានរកឃើញថា ឆ្លងជំងឺកូវីដ១៩ នៅកម្ពុជានេះ រួមមាន:

ទី១: បុរសជនជាតិចិន មកពីទីក្រុងវូហាន (ជាសះស្បើយហើយ)

ទី២: បុរសជនជាតិខ្មែរ វ័យ៣៨ឆ្នាំ នៅខេត្តសៀមរាប

ទី៣: ស្ត្រីជនជាតិអង់គ្លេស វ័យ៦៥ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅ ខេត្តកំពង់ចាម (ជាសះស្បើយហើយ)

ទី៤: បុរសជនជាតិអង់គ្លេស វ័យ៧៣ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៥: ស្រីជនជាតិអង់គ្លេស វ័យ៦៩ឆ្នាំ អ្នកដំណើរនាវា Viking Cruise Journey នៅខេត្តកំពង់ចាម

ទី៦: បុរសជនជាតិកាណាដា អាយុ៤៩ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៧: បុរសជនជាតិបែលហ្ស៊ិក អាយុ៣៣ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៨: បុរសជនជាតិបារាំង អាយុ៣៥ឆ្នាំ នៅរាជធានីភ្នំពេញ

ទី៩: ទារកជនជាតិបារាំង អាយុ៤ខែ នៅរាជធានីភ្នំពេញ

ទី១០: បុរសជនជាតិខ្មែរ នៅរាជធានីភ្នំពេញ

ទី១១: បុរសជនជាតិខ្មែរ នៅខេត្តព្រះវិហារ អាយុ៣៥ឆ្នាំ នៅខេត្តព្រះវិហារ

ទី១២: បុរសជនជាតិខ្មែរ អាយុ៣៩ឆ្នាំ នៅខេត្តព្រះវិហារ។ តទៅទំព័រទី០៧




# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
**Sokharith Mey, M.D.**

លោក ឆាន់ ទូច , C.N.P.
**Chhan Touch, C.N.P.**





## ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

## Now Accepting New Patients

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហេល្ធ មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

តមកពីទំព័រទី ០៥

# ក្រសួងសុខាភិបាលរកឃើញអ្នកផ្ទុក...

ទី១៣: បុរសជនជាតិខ្មែរ នៅក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

ទី១៤: បុរសជនជាតិខ្មែរ មកពីប្រទេសថៃ នៅភូមិព្រៃឫស្សី ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

ទី១៥, ទី១៦: បុរសជនជាតិខ្មែរ ២នាក់ (អាយុ ៦៣ឆ្នាំ និង៦៤ឆ្នាំ) នៅព្រែកប្រា

ទី១៧, ១៨, ១៩, ២០: បុរសជនជាតិខ្មែរ (អាយុចន្លោះពី ៣៨ឆ្នាំ ដល់ ៤៥ឆ្នាំ) នៅក្នុងខេត្តបាត់ដំបង

ទី២១: បុរសជនជាតិខ្មែរ អាយុ ៣០ឆ្នាំ នៅក្នុងខេត្តកំពត បច្ចុប្បន្នដាក់ព្យាបាលនៅមន្ទីរពេទ្យខេត្តកែប

ទី២២: បុរសជនជាតិខ្មែរ អាយុ ៦១ឆ្នាំ នៅខេត្តត្បូងឃ្មុំ បច្ចុប្បន្នដាក់ក្នុងមន្ទីរពេទ្យខេត្តនៅពញាក្រែក

ទី២៣: បុរសជនជាតិខ្មែរ អាយុ ៧៥ឆ្នាំ នៅខេត្តកំពង់ឆ្នាំង ត្រូវបានដាក់ឱ្យព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។

ទី២៤: បុរសជនជាតិខ្មែរ អាយុ ២៨ឆ្នាំ នៅខេត្តកំពង់ឆ្នាំង ត្រូវបានដាក់ឱ្យព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។

ទី២៥: បុរសជនជាតិខ្មែរ អាយុ៤០ឆ្នាំ នៅខេត្តសៀមរាប

ទី២៦ និង២៧: បុរសជនជាតិខ្មែរ ២នាក់ នៅរាជធានីភ្នំពេញ

ទី២៨: បុរសជនជាតិខ្មែរ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង អាយុ៣៦ឆ្នាំ

ទី២៩, ៣០ និង៣១: ជនជាតិម៉ាឡេស៊ី៣នាក់ នៅខេត្តកែប

ទី៣២: បុរសជនជាតិខ្មែរ នៅខេត្តកោះកុង

ទី៣៣: បុរសជនជាតិខ្មែរនៅខេត្តត្បូងឃ្មុំ អាយុ៩៣ឆ្នាំ។

ទី៣៤: ជនជាតិម៉ាឡេស៊ី នៅខេត្តកំពត

ទី៣៥: ជនជាតិម៉ាឡេស៊ី នៅខេត្តកំពត

ទី៣៦: ជនជាតិខ្មែរ អាយុ៧១ឆ្នាំ នៅខេត្តត្បូងឃ្មុំ

ទី៣៧: ជនជាតិខ្មែរ អាយុ៩២ឆ្នាំនៅខេត្តត្បូងឃ្មុំ។

ទី៣៨: ស្ត្រីអាយុ៣៥ឆ្នាំ ដែលឆ្លងពីប្តីរបស់គាត់ នៅខេត្តបាត់ដំបង

ទី៣៩: ស្ត្រីអាយុ៤១ ដែលឆ្លងពីប្តីរបស់គាត់នៅខេត្តបាត់ដំបង



ទី៤០: បុរសអាយុ៦០ឆ្នាំ នៅខេត្តកណ្តាល

ទី៤១: បុរសអាយុ៣៤ឆ្នាំ នៅសង្កាត់ច្បារអំពៅ រាជធានីភ្នំពេញ

ទី៤២: បុរសជនជាតិម៉ាឡេស៊ី អាយុ២៦ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាសខេត្តកំពង់ចាម

ទី៤៣: បុរសជនជាតិម៉ាឡេស៊ី អាយុ៣៤ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាស ខេត្តកំពង់ចាម

ទី៤៤: បុរសជនជាតិម៉ាឡេស៊ី អាយុ៣៤ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាស ខេត្តកំពង់ចាម

ទី៤៥: បុរសជនជាតិម៉ាឡេស៊ី អាយុ៥១ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាស ខេត្តកំពង់ចាម

ទី៤៦: បុរសជនជាតិម៉ាឡេស៊ី អាយុ៤៨ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាស ខេត្តកំពង់ចាម

ទី៤៧: បុរសជនជាតិម៉ាឡេស៊ី អាយុ៦២ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នស្រុកកងមាស ខេត្តកំពង់ចាម។

ទី៤៨: ជនជាតិម៉ាឡេស៊ី អាយុ៣៩ឆ្នាំ ធ្វើការងារ ផ្សព្វផ្សាយសាសនា នៅខេត្តកំពង់ចាម

ទី៤៩: ជនជាតិខ្មែរ អាយុ៣៣ឆ្នាំ ដែលបានឆ្លងបន្តពីបុរសម្នាក់ដែលមានវិជ្ជមានកូវីដ១៩ ពេលវិលត្រឡប់ពីប្រទេសម៉ាឡេស៊ីចូលមកកម្ពុជា

ទី៥០: បុរសខ្មែរអាយុ៤៨ឆ្នាំ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលត្រឡប់ពីបុណ្យសាសនានៅប្រទេសម៉ាឡេស៊ី

ទី៥១: បុរសខ្មែរអាយុ៣៨ឆ្នាំ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលត្រឡប់ពីបុណ្យសាសនានៅប្រទេសម៉ាឡេស៊ី។

ទី៥២: អ្នកទេសចរជនជាតិបារាំង អាយុ៦៧ឆ្នាំ ដែលចូលទៅខេត្តព្រះសីហនុ

ទី៥៣: អ្នកទេសចរជនជាតិបារាំង អាយុ៨០ឆ្នាំ ដែលចូលទៅនៅខេត្តព្រះសីហនុ។

ទី៥៤-ទី៨២: ជនជាតិបារាំង២៩នាក់ ក្នុងនោះ ស្ត្រី១៧នាក់ មាន ១អាយុ៤៤ឆ្នាំ ៥៩ឆ្នាំ ៦៦ឆ្នាំ ៦១ឆ្នាំ ៦៣ឆ្នាំ ៥២ឆ្នាំ ៦៦ឆ្នាំ ៥៩ឆ្នាំ ៦៣ឆ្នាំ ៧៦ឆ្នាំ ៦០ឆ្នាំ ៦៣ឆ្នាំ ៦៩ឆ្នាំ (២នាក់) និង៥៩ឆ្នាំ និងបុរស១២នាក់ មានអាយុ៦៦ឆ្នាំ ៥៧ឆ្នាំ ៧០ឆ្នាំ (២នាក់) ៦៣ឆ្នាំ (៣នាក់) ៥២ឆ្នាំ ៦៤ឆ្នាំ ៦២ឆ្នាំ ៦១ឆ្នាំ និង៥៨ឆ្នាំ។

ពួកគេស្នាក់នៅសណ្ឋាគារខេត្តព្រះសីហនុ

ទី៨៣: ជនជាតិខ្មែរ អាយុ៣៥ឆ្នាំ ជាអ្នកនាំភ្ញៀវទេសចរបារាំងដើរកម្សាន្ត

ទី៨៤: ជនជាតិខ្មែរអាយុ៣៣ឆ្នាំ ជាអ្នកនាំភ្ញៀវទេសចរបារាំងដើរកម្សាន្ត។

Freshnews

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ិន រាលអ៊ីស្តេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន

ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Residential Leasing Center
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business
508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com


# Fast Facts about Corona Virus

*/From Page 02*

package is being introduced and expected to vote this week in the senate to bail out the US economy and offer family cash assistance to cope from the layoffs and closures, to develop and purchase medical supplies for community hospitals in efforts to stop the spread of the disease. On Wednesday, the Corona Virus Relief Bill was signed into law by the president and already went into affect — including paid sick leave and Free Covid-19 testing.

Many experts believe the corona virus is the worst pandemic impact they have seen since 1918 and may have greater economic impact than the 2008 crisis.



Sethy Pao, Owner of Angkor Thom

**News & Information**

CDC — Center for Disease Control released a statement that advised everyone to practice "social distancing" to help stop the Corona virus. What social distancing basically means is that you have to stand 6" feet away from each other in order to avoid breathing in the water droplets of another person who may be infected. Because it is a respiratory infectious disease, it is transmitted by touching, coughing, or sneezing. You do not have to wear mask if you have not been tested positive of corona virus. Wearing mask does not protect you; washing hands and using other disinfected FDA approved products will. In this print, we gathered a list of FDA products which you can buy to help your household clean since there hasn't been any re-stock of hand sanitizers in the last two weeks. There also no more toilet tissue rolls. We think this purchase was likely just out of fear because if someone gets sick, they would need tissue paper, when there is



MA Governor Charlie Baker

no tissue paper, toilet tissue paper is the next softest thing. However, it is very unlikely you need will it. What you need is to try to go about your ev-







ery day as normal as possible, with a set of schedule to help kids stay home and healthy in the next few weeks until further notices.

**Khmer Post USA Recommendations**

For weeks, we have been following the news and we are recommending our audience the following how to keep your family healthy and safe.

- Make healthy home meals daily
- Go to the state, national parks for hiking and/or walking to keep your regular exercise and for stress relief during this anxious time
- Read books, news/magazine and /or watching Netflix family movies together
- Cut down reading newsfeed on Facebook or on any other social media platforms about corona virus
- Consume just enough formal information about corona virus news to help you make healthy decisions for you and your family
- News sources and website we recommend to go to are including major source like Time Magazine which has weekly report, or New York Times has updates daily and government website such Center for Disease Control has the most up to date information and health advisory at www.cdc.gov
- For private school students, it's still regular school days at home. Follow the syllabus sent by the teacher.




**What's open**

This pandemic is affecting our economy very quickly and severely. However, I find the spirit of our community business owners are still optimistic. Sethy Pao, Owner of Angkor Thom market said "it's okay, we can take the lost. Our lost is much smaller comparing to the airline company which lost millions of dollars. And we're not afraid of the coronavirus. Although our restaurants are closed, our market continue to open to serve our customers". On Sunday March 22nd, I took a tour in the Lowell Cambodia Town to find which stores are open or closed. Here is a list I've found and wanted to share with our audience. Cambodian groceries are open including Bangkok Market, Bayon Market, K-Market, and Hong Kong Market. The number of customers are slightly higher volume than usual. Cambodian restaurants that are open including Simply Khmer. Red Rose is available for take out only. Lowell restaurant, Phnom Penh restaurant and Pepuptmei are closed. Yummy Express is also closed.

Function halls are closed including Sampao Meas Hall, Sunnyda, and Pailin City — that means there will be no Cambodian New celebration this year. The annual Cambodian New Year celebration at the Pailin Park also has been cancelled. The U.S. president ordered that no more than two dozens people can gather together. Governor Charlie Baker ordered a stay-at-home advisory and all non-essential businesses in the state to close in order to avoid spreading the virus. "Everyone should know that we will always allow essential businesses to remain open" said Governor Baker. Essential businesses including pharmacies, grocery stores and businesses that support them will remain open, gas station, manufacture medical equipment, no prohibiting travel, roads, bridges, tunnels and public transportation are open. "We urge people to stay at home and avoid any unnecessary activity because this will help avoid any unneeded person-to-person interaction that can spread the virus" said Governor Baker. Go to www.mass.gov/covid19 for more information on business category which are considered essential.

**The New Reality**

In closing, I know for many Cambodians dealing with this new reality it must feel like preparing for a war crisis again, buying and stocking foods, keeping your family inside the house etc. Please know that we are all in this together. We are here to support one another and please make welfare check on friends and family, if not by physical visit, at least by phone calls or text messages may help reduce anxiety and social isolation. Stay warm and stay safe. Our phone line is open to hear your story and how you are doing at 978-656-8141 or you may write to us at khmerpostusa@gmail.com

# ការណែនាំពីផលិតផលដើម្បីកម្ចាត់មេរោគកូវីត_១៩

ខណៈនៃការផ្ទុះរីករាលដាលនៃមេរោគកូវីត ១៩ កើតឡើងស្ទើរតែទូទាំងពិភពលោកដោយបានចាប់ផ្តើមដំបូងបំផុតពីប្រទេសចិនហើយ បច្ចុប្បន្នអ៊ីរ៉ុដែលកំពុងរងគ្រោះខ្លាំងជាងគេដោយមានចំនួននាក់ឆ្លង នឹងស្លាប់កើនឡើងជាបន្ត បន្ទាប់ពីប្រទេសចិននោះទីភ្នាក់ងារការពារបរិដ្ឋានអាមេរិចកាលពីពេលថ្មីនេះបានធ្វើការផ្សព្វផ្សាយព័ត៌មានដ៏មានសារៈសំខាន់បំផុតមួយទាក់ទងនឹងផលិតផលដែលមានផ្ទុកសាធាតុសំលាប់មេរោគ រឺបាក់តេរី ដើម្បីជួយកាត់បន្ថយការរីកសាយភាយនៃមេរោគកូរ៉ូណា រឺកូវីត ១៩។

បើតាមអ្នកវិទ្យាសាស្ត្រខាងផ្នែកសុខាភិបាលបានរកឃើញថា ដោយសារតែប្រភេទមេរោគកូរ៉ូណាវីរុសនេះគឺជាប្រភេទមេរោគដែលស្រោម ព័ន្ធជុំវិញរាងដូចរង្វង់ (enveloped viruses) ដូច្នេះវាងាយស្រួលបំផុតក្នុងការសម្លាប់ជាមួយនឹងផលិតផលដែលមានសារធាតុសម្លាប់មេរោគ រឺបាក់ តេរី។ បើយោងតាមមជ្ឈមណ្ឌលពិនិត្យ និងទប់ស្កាត់ជំងឺឆ្លង (CDC) បានឱ្យដឹងថា ការប្រើ




ប្រាស់ផលិតផលរំងាប់មេរោគ,ទឹកអាគុលដែលមានរំលិតយ៉ាងហោចណាស់ 70%, ទឹកលាងសម្អាតមេរោគ និងសារធាតុសម្លាប់មេរោគ ឬបាក់តេរី ដែលបានចុះបញ្ជីនៅទីភ្នាក់ងារការពារបរិដ្ឋានអាមេរិច(EPA) គឺអាចប្រើប្រាស់បានប្រកបដោយប្រសិទ្ធភាព។

ផលិតផលដែលបានចុះបញ្ជីជាមួយនឹង EPA ដែលយើងអាចយកមកប្រើប្រាស់សម្រាប់កម្ចាត់មេរោគនេះមានដូចខាងក្រោម:

- Clorox Disinfecting Wipes
- Clorox Commercial Solutions
- Clorox Disinfecting Spray
- Clorox Multi-Surface Cleaner + Bleach
- Klercide 70/30, Lonza Formulation
- Lysol Clean & Fresh Multi-Surface Cleaner
- Lysol Disinfectant Max Cover Mist
- Lysol Heavy-Duty Cleaner Disinfectant Concentrate
- Oxycide Daily Disinfectant Cleaner
- Peak Disinfectant Wipes
- Peroxide Multi Surface Cleaner and Disinfectant
- Peroxide Disinfectant and Glass Cleaner
- Purell Professional Surface Disinfectant Wipes
- Sani-Prime Germicidal Disposable Wipe
- និង Sani-Prime Germicidal Spray .

ប៉ុន្តែអ្នកប្រើប្រាស់ គួរតែធ្វើតាមការណែនាំ និងត្រូវយកចិត្តទុកដាក់ចំពោះរយៈពេលដែលតម្រូវឱ្យប្រើផលិតផលទាំងនេះដើម្បីឱ្យមានសកម្មភាពនៃការសម្លាប់មេរោគកើតឡើងនៅកន្លែងដែលបានលាប រឺជូតសម្អាតនោះ។

ជាមួយគ្នានោះដែរក្រុមប្រឹក្សាផ្នែកគីមីវិទ្យាអាមេរិក ដែលហៅថា The Amercian Chemsitry Council ក៏បានបង្ហាញពីបញ្ជីឈ្មោះផលិតផលដែលសមស្របអាច ប្រើប្រាស់ប្រឆាំងមេរោគ Enveloped viruses ព្រមទាំងអាចប្រើក្នុងកំឡុងពេលនៃការផ្ទុះមេរោគកូរ៉ូណាវីរ៉ុស (ខូវីត-១៩) ផងដែរមានដូចជា:

- Cosa Oxonia Active
- Microban 24 Hour Multi-Purpose Cleaner
- Microban 24 Hour Bathroom Cleaner
- Lemon Disinfectant
- Cosa Oxonia Active
- Clear Gear Sports Spray
- Foster First Defense
- Sani-Spritz Spray
- Don-O-Mite
- One-Step Disinfectant Cleaner
- X-Ray Apron Cleaner Disinfectant
- All Purpose Virex
- SaniZide Pro 1 Spray
- Maxim GSC Germicidal Spray Cleaner
- Bright Solutions Lemon Zip Disinfectant
- Simple Green Clean Finish
- TB Quat Disinfectant
- Bioesque Solutions Botanical Disinfectant Solution
- REScue Ready to Use One Step Disinfectant Cleaner & Deodorizer
- Zep Spirit II
- Zep Antibacterial Disinfectant & Cleaner
- Zep Quick Clean Disinfectant
- Stepan Spray Disinfectant Concentrate
- Buckeye Sanicare Lemon Quat
- 3M Quat Disinfectant Cleaner Concentrate
- Symplicity Sanibet Multi-Range Sanitizer
- Pine Quat
- Quaternary Disinfectant Cleaner
- TruShot Disinfectant Cleaner for Hospitals
- TruShot Disinfectant Cleaner Restroom Cleaner & Disinfectant
- Formula 17750 Wintermint Formula 17822 Deo-Clean Multi
- Neutra-Tec 64

DAN O'BRIEN | DAN O'BRIEN

សូមស្វាគមន៍ និងសូមមកកាន់ភ្នាក់ងារលក់ ដើម្បីទិញរថយន្តថ្មីរបស់អ្នកនៅថ្ងៃនេះ! យើងមានការបញ្ចុះតម្លៃរាប់រយគ្រឿងនៃរថយន្តថ្មី និងរថយន្តប្រើប្រាស់រួចៗ ដូចជា sedans, jeeps, និង mini vans នៅក្នុងស្តុករបស់យើងៗ ទស្សនាទីតាំងរបស់យើងដែលនៅជិតអ្នកបំផុត ឬទូរស័ព្ទ វុទ្ធី យក់ សសម្រាប់រត់ជួប



Vuthy Yok វុទ្ធី យក់
Sales and Leasing Consultant
Office (978) 746-2500 Ext. 58316
Cell (978) 621-3842
vyok@danobrienautogroup.com




- One Year Maintenance Included
- One Year Paintless Dent Repair
- Free Safety Inspections for you and your entire household
- Lifetime Power-train Warranty

DAN O'BRIEN NISSAN
95 DRUM HILL ROAD,
CHELMSFORD, MA 01824
http://www.DanOBrienNissan.com

DAN O'BRIEN CDJR
175 PELHAM ST,
METHUEN, MA 01844
https://www.danobriencdjr.com

KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com



Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com
ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA




# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រឺការមើលការខុសត្រូវក្នុងកំឡុង ពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្មុកស្មាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺឱ្យមានអ្នកមកមើលថែអ្នកដែលជា ស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយវ៉ឺរស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការទាក់ទងនឹងមនុស្សឯទៀត, រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នក ដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់ មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប, ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្វាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌលថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នកមិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជុំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរាបង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទឹមរង់ចាំក្នុងការទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្ត្រ។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ និងនំចំណីបំប៉នច្រើន
- ថ្នាក់កីឡារជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពដាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា DADC**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពិននីស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលផ

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ជាឯកជន
- ទទួលយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស, ស្ពេននីស, ខ្មែរ, ឡាវ, ម៉ោង, បំទុយក្តាល់, សូវៀត និងតាហ្គាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹង ផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រង មេឌីឃេត សម្រាប់សេវាថាទាំចាស់ជរាលោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។

# សង្គ្រាមរួម

ដោយ ពិន សំខុន

វាដូចជាចៃដន្យពេកណាស់ ដែលជម្ងឺអាសន្នរោគ"កូវីដ១៩" បានធ្វើឱ្យពិភពលោកភិតភ័យស្លន់ស្លោខិតខំកាពារប្រទេសរបស់គេតែរៀង១ខ្លួន។ ប្រទេសប្រមាណ១៥០ ក្នុងចំណោមប្រទេសជិត ២០០ ក្នុងលោកបានទទួលរងគ្រោះដោយជម្ងឺអាសន្នរោគ"កូរ៉ូណា១៩"នេះ ហើយ នេះ គឺជា"សង្គ្រាមជីវសាស្ត្ររួម"បង្កើតឡើងដោយធម្មជាតិនៅក្រុងវូហាន នៃប្រទេសចិន។ អាជ្ញាធរចិន ដែលមិនជឿពីដំបូងបានខិតខំលាក់បាំងពីវត្តមាននៃជម្ងឺនេះ ដោយសារតែការខ្មាសអៀន តែទប់មិនជាប់ដោយជម្ងឺបានរាលដាលពេញទាំងប្រទេសទៅឆ្លងដល់ប្រទេសដ៏ទៃថែមទៀត ក៏ទម្លាយរឿងដ៏គ្រោះថ្នាក់នេះ ឱ្យពិភពលោកដឹង។ រីឯប្រទេសខ្មែរជាប្រទេសតែមួយ ដែលមេដឹកនាំដ៏មានអំណាច ហ៊ុន សែន មិនព្រមជឿដល់វត្តមាននាំជំងឺនេះ ពីព្រោះតែចង់ការពារមុខមាត់នៃប្រទេសចិន"ជាមហាមិត្ត" ក៏ខិតខំធ្វើអំពើដែលមិនគួរធ្វើ ចំពោះប្រជាជាតិខ្លួនឯង ដោយ"ចាក់ផុក"តម្លៃជីវិតនៃប្រជាជនខ្មែរ ចំពោះជំនឿដ៏ក្រអឺតក្រទមនេះ។


សម្តេច ហ៊ុន សែន


លោក ហ៊ុន ម៉ាណែត


អតីតប្រធានាធិបតីចិន ម៉ៅ សេទុង


លោក ចាងកាយិក

ក្រៅតែពីបក្សប្រឆាំងនឹងគ្រួសារអ្នករងគ្រោះតិចតួចបានចេញមុខមកបង្ហាញការពិត តាមរយប្រព័ន្ធផ្សព្វផ្សាយសង្គម ពីទំហុំវិបត្តិនៃ"កូវិដ១៩" រំលងអំណាចនៃលោក ហ៊ុន សែន ដ៏អស្ចារ្យម្នាក់នេះ, ក្នុងចំនួននោះ ក៏មានលោក ហ៊ុន ម៉ាណែត ជាឧត្តមសេនីយកងទ័ព កូនប្រុសលោក ហ៊ុន សែន ដែលបានទិទាន ពីការភូតភររបស់ក្រសួងសុខាភិបាល លោក ហ៊ុន សែន ចំពោះការប្រយុទ្ធប្រឆាំងនឹង "កូវិដ១៩"នេះដែរ។

ការទិទាននេះ បានបង្អើលការចាប់ផ្តើមបន្ថយសម្លេង ដែលគ្មានអ្នកណាជឿរបស់រដ្ឋបាលលោក ហ៊ុន សែន... តែគេនៅតែជឿថា "កូវីដ១៩"នៅ តែរាតត្បាតកម្ពុជាយ៉ាងខ្លាំងក្លានៅឡើយ។ បន្ទាប់មក ក៏ចំនួនអ្នករងគ្រោះ បាន"ប្រកាស"កើនឡើងជំនួយសង្គ្រោះមកពីខាងប្រទេសចិន ក៏មកដល់ក្នុងចំនួនតិចតួច។ ទោះជាយ៉ាងនេះក្តី ក៏គេនៅតែជឿថា ចំនួនដែលផ្សព្វផ្សាយថ្មីនោះ នៅតែតិចជាង "ចំនួនពិត"តែដដែល ពីព្រោះគេនៅតែចងចាំថាកាលពីជំនាន់ជម្ងឺ"អេដ" នាឆ្នាំ២០០១,២ ក្រសួងសុខាភិបាលដដែលនេះ បានលាក់ចំនួនអ្នករងគ្រោះដ៏សន្ធឹកសន្ធាប់ដោយមានការប្រយុទ្ធប្រឆាំងនឹងការពារតិចតួច។ ប្រទេសលោកសេរីក៏គេចូលមកជួយតិចតួចដូចគ្នានេះក៏ ដោយសារតែ១ គេមិនដឹងច្បាស់លាស់ពីស្ថានភាពរាលដាលជម្ងឺនៅកម្ពុជាយើង២ គេរវល់នៅប្រទេស ដែលគេបានដឹងព័ត៌មានច្បាស់លាស់ជាខ្មែរ។

ជាថ្មីម្តងទៀត ជម្ងឺអាសន្នរោគដែលមានឈ្មោះថា "កុវិដ១៩"នេះ បានក្លាយទៅជា មហារាតត្បាតPandemy ទៅហើយដូច្នេះតម្រូវឱ្យខ្មែរគ្រប់រូបប្តូរអិរិយាបទយកការរួបរួមកម្លាំងគ្នា ដើម្បី "បញ្ចប់ការរាតត្បាតនៃជម្ងឺដ៏សាហាវ"នេះ ជាបន្ទាន់។ គណបក្សប្រឆាំងត្រូវត្រឡប់មកកាន់ឥរិយាបទដែលជាប្រយោគមេបក្សប្រឆាំង កឹម សុខា ថា "មិនយកខ្មែរណាជាសត្រូវ"បញ្ចប់ការទិទាន ដែលគ្មានប្រយោជន៏ជាងជីវិតប្រជាពលរដ្ឋខ្មែរ, រីឯគណបក្សកាន់អំណាច ក៏គួរតែចុះសម្រុងគ្នាឯង ហើយបើកទ្វារឱ្យខ្មែរគ្រប់រូបអាចចូលទៅជួយសង្គ្រោះបងប្អូនគេបានផង, ពេលនោះជំនួយសុខភាពពីប្រទេសលោកសេរី នឹងធ្លាក់មកជាបន្តបន្ទាប់ទៅតាមព័ត៌មានពិត ដែលគេជឿបាន ។

នៅពេលនោះ ភារៈកិច្ចជាបន្ទាន់នោះ នឹងក្លាយជាសកម្មភាពរួមគ្នាជាលើកដំបូងគឺ ១-សង្គ្រោះដល់អ្នក **តទៅទំព័រទី ១៣**






# វិធីសាស្ត្រកាត់បន្ថយអារម្មណ៍តានតឹងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ១៩ (Covid-19)

ភ្នំពេញ: នៅពេលនេះ ជំងឺរលាកផ្លូវដង្ហើមប្រភេទថ្មី ឬ Coronavirus Disease-19(Covid-19)កំពុងរាតត្បាតស្ទើរពេសពេញពិភពលោក (Pandemic) ។ ស្ថិតក្នុងស្ថានការណ៍បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំប្រទេសអង្គការជាតិអន្តរជាតិនានាទូទាំងសកលលោកបានចាត់វិធានការណែនាំអប់រំផ្សព្វផ្សាយប្រជាជន និងចេញវិធានការតឹងរឹងមួយចំនួនជាចាំបាច់ដើម្បីទប់ស្កាត់ការចម្លងរាតត្បាតនៃមេរោគរលាកផ្លូវដង្ហើមថ្មីនេះកាន់តែធ្ងន់ធ្ងរ ។

នេះបើតាមការផ្សាយព័តិមានរបស់រាជបណ្ឌិតសភាកម្ពុជា នៅថ្ងៃទី១៩ ខែមីនា នេះ ។

វិធានការនានាដែលត្រូវអនុវត្តទាំងនោះ រួមមាន ការផ្អាកការឆ្លង កាត់ព្រំដែនរវាងប្រទេស និងប្រទេសទាំងផ្លូវគោក ទឹក និងអាកាសការដាក់ឱ្យអនុវត្តវិស្សមកាលមុនកាលកំណត់នៅតាមគ្រឹះស្ថានគ្រប់កម្រិតសិក្សា ការផ្អាក ពិធីជួបជុំសាសនានានា បិទរោងភាពយន្ត និងកន្លែងជួបជុំកម្សាន្តនានា ។

ក្នុងអំឡុងពេលនៃការរាតត្បាត Covid-19 ជាសកល ចង់ឬពុំចង់ តិច ឬច្រើន វិធានការខាងលើនេះប្រាកដជានាំឱ្យមានផលប៉ះពាល់ដល់អារម្មណ៍របស់ប្រជាជន



ទូទាំងពិភពលោកដែលអាចនាំឈានទៅដល់ជំងឺថប់បារម្ភកាន់តែស្មុគស្មាញខ្លាំងឡើងអំពីស្ថានភាពនៃការរាតត្បាតនៃមេរោគផងព្រួយបារម្ភអំពីសុខភាពផ្ទាល់ខ្លួនផង និងសុខភាពរបស់មនុស្សជាទីស្រលាញ់របស់ខ្លួនផង។ ជាការឆ្លើយតបទៅនឹងស្ថានភាពខាងលើនេះ

អង្គការសុខភាពពិភពលោក (WHO) និងក្រសួងសុខាភិបាលបានណែនាំអំពីវិធីសាស្ត្រជាគន្លឹះមួយចំនួនដើម្បីជួយប្រជាជនរស់នៅលើសកលលោកឱ្យកាត់បន្ថយអារម្មណ៍ធុញថប់ដោះស្រាយភាពតានតឹងក្នុងបរិបទនៃការរស់នៅបែបថ្មីដំណាក់កាលផ្ទុះរាតត្បាតជំងឺកូវីដ១៩ នេះ ដែលមានខ្លឹមសារដូចខាងក្រោម:

១.អំឡុងពេលមានវិបត្តិជាធម្មតាអ្នកមានអារម្មណ៍ទុក្ខព្រួយសោកសៅតានតឹងផ្លូវចិត្ត ច្របូកច្របល់ ភ័យខ្លាច ឬខឹងមួរម៉ៅជាដើម ។

សូមនិយាយជជែកជាមួយមនុស្សដែលអ្នកទុកចិត្ត ដូចជា មិត្តភក្តិ និងក្រុមគ្រួសារ ។

២.ប្រសិនបើអ្នកត្រូវតែសម្រាកនៅផ្ទះ សូមរក្សារបៀបរស់នៅប្រកបដោយសុខភាពល្អ រួមមានបរិភោគអាហារឱ្យបានត្រឹមត្រូវ គេងឱ្យបានគ្រប់គ្រាន់ ហាត់ប្រាណឱ្យបានទៀងទាត់ ហើយរក្សាទំនាក់ទំនង

តទៅទំព័រទី១៣










តមកពីទំព័រទី ០៣

## វិធីសាស្ត្របន្ថយអារម្មណ៍តានតឹង...

ក្នុងសង្គមជាមួយមនុស្សជាទីស្រលាញ់នៅផ្ទះរបស់អ្នក ឬតាមរយៈសារអ៊ីម៉ែលទូរស័ព្ទ និងបណ្តាញសង្គមនានាជាមួយក្រុមគ្រួសារ និងមិត្តភក្តិដទៃ។

៣.សូមកុំពិសាបារី គ្រឿងស្រវឹង ឬសារធាតុញៀនផ្សេងៗ ដើម្បីដោះស្រាយភាពតានតឹងផ្លូវចិត្តរបស់អ្នក។

ប្រើជំនាញ ឬរបៀបដោះស្រាយទាំងនោះមកដោះស្រាយភាពតានតឹងផ្លូវចិត្តរបស់អ្នកក្នុងអំឡុងពេលនៃការផ្ទុះរាតត្បាតជំងឺកូវីដ១៩នេះ។

សូមជម្រាបជូនថា វីរុសកូរ៉ូណាប្រភេទថ្មី (CoV) គឺជាវីរុសថ្មីនៃអម្បូរវីរុសកូរ៉ូណា។

វីរុសកូរ៉ូណាប្រភេទថ្មីនេះត្រូវបានគេរកឃើញដំបូងនៅក្នុងទីក្រុងវូហាន ប្រទេសចិន ដែលត្រូវបាន



៤. សូមស្វែងរកព័ត៌មានពិត ដែលអាចជួយអ្នកធ្វើការសម្រេចចិត្តទៅលើហានិភ័យដោយភាពត្រឹមត្រូវ ដូចជា គេហទំព័រ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ឬហ្វេសប៊ុករបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬហ្វេសប៊ុករបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ឬគេហទំព័ររបស់អង្គការសុខភាពពិភពលោក។

៥. កាត់បន្ថយការព្រួយបារម្ភ និងភាពឡេះឡាស់ ដោយកាត់បន្ថយការមើល ឬស្តាប់ប្រព័ន្ធផ្សព្វផ្សាយនានាដែលអ្នកយល់ថា ធ្វើឱ្យអ្នកកាន់តែពិបាកចិត្ត។

៦.សូមប្រើប្រាស់ជំនាញក្នុងការជួយដោះស្រាយរឿងរ៉ាវ បញ្ហា ជីវិតមិនល្អកន្លងមក ហើយ

គេដាក់ឈ្មោះថាជំងឺវីរុសកូរ៉ូណាឆ្នាំ២០១៩ (កូវីដ ១៩,COVID-19) ដែលពាក្យកាត់ "CO" តំណាងឱ្យពាក្យ Corona (កូរ៉ូណា) "VI" តំណាងឱ្យពាក្យវិរុស (វីរុស) និង "D" តំណាងឱ្យពាក្យ disease (ជំងឺ)។ កាលពីមុន ជំងឺនេះត្រូវបានគេហៅឈ្មោះថា"វីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ២០១៩" ឬ "COVID-19"។

ជាសញ្ញាល្អមួយដែរ អ្នកវិទ្យាសាស្ត្រទូទាំងពិភពលោកបានបង្ហាញជំនឿជាក់យ៉ាងមុតមាំថា ថ្នាំ និងវ៉ាក់សាំងព្យាបាលជំងឺកូវីដ ១៩នេះនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលដ៏ឆាប់ៗខាងមុខនេះ។ ដោយៈកូឡាប CEN

តមកពីទំព័រទី ១១

## សង្គ្រាមរួម

ដែលឆ្លងជម្ងឺឱ្យទទួលការព្យាបាលត្រឹម ត្រូវ ២-ការពារគ្រួសារខ្មែរកុំឱ្យជម្ងឺឆ្លងទៅអ្នកដទៃបាន ៣-ជួយក្រសួងសុខាភិបាលខ្មែរឱ្យមានសមត្ថភាពព្យាបាលដល់គ្រប់ទីកន្លែង ៤-ជួយដល់ពលរដ្ឋឱ្យអាចទទួលព័ត៌មានត្រឹមត្រូវនឹងគ្រប់គ្រាន់ ៥-ចុងបញ្ចប់ គឺជួយជួសជុលសេដ្ឋកិច្ចគ្រួសារ ដែលបានទទួលការខូចខាតពីជម្ងឺកូវីដ១៩នេះ។

ថ្វីត្បិតតែជាវិបត្តិសង្គមធំធេងក៏ដោយក្តី តែ "កូរ៉ូណាវ៉ាយរ៉ុស"នេះ ក៏អាចជា"ឱកាសព្យាបាលជម្ងឺនយោបាយខ្មែរ"បានដែរ ប្រសិនបើយើងដាក់ខ្លួនជា"អ្នកស្នេហាជាតិ" ហើយស្គាល់ឱកាសសម្រាប់ជួយប្រជាជាតិឱ្យបានរស់រានមានជីវិត...នៅប្រទេសអ៊ីរ៉ង់ គេដោះលែងអ្នកទោសនយោបាយ៨០០០នាក់ បន្ទាប់ពីជម្ងឺនេះ បានយកជីវិតពលរដ្ឋគេអស់ច្រើនពាន់នាក់, ត្រឡប់ទៅអតីតកាល ដូចជាឧទាហរណ៍នៃប្រវត្តនៅប្រទេសចិន ដែលក្រុមចិន



លោក កឹម សុខា

សេរី "ជៀងកាយជាក" សម្រេចបន្ទាន់ថា "ឈប់វាយប្រហារគ្នា"ជាមួយ"ក្រុមចិនកុម្មុនិស្ត ម៉ៅសេទុង" នាអំឡុងឆ្នាំ១៩៤០ ដើម្បីបណ្តេញជប៉ុន ឈ្លានពានចេញពីប្រទេស... គេក៏នាំគ្នាធ្វើបានសម្រេចនៅចុងបញ្ចប់ "ការពារទឹកដីចិនបាន"មែន។

## សេចក្តីជូនដំណឹងស្តីពី ការរៀបចំកិច្ចប្រជុំជាសាធារណៈ និងឱកាស ក្នុងការផ្តល់មតិយោបល់ នៅលើពង្រៀង វិសោធនកម្មគម្រោង កម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ២០២០-២០២៤ របស់ អង្គភាព រៀបចំក្រុង ន័សធន ម៉ីដូលសិច

អង្គភាពរៀបចំក្រុង ន័សធន ម៉ីដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO បានប្រកាសផ្សព្វផ្សាយដើម្បីឱ្យសាធារណៈជនធ្វើការផ្តល់ជាមតិយោបាលទៅលើពង្រៀងវិសោធនកម្មចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០២០-២០២៤ ។ សំណើរពង្រៀងវិសោធនកម្មនេះមានរួមបញ្ចូលទាំងថវិការការរៀបចំផែនការសម្រាប់គម្រោងពង្រីកMerrimack Riverwalk នៅក្នុងក្រុងឡូផងដែរ។

លោកអ្នកអាចចូលអានសេចក្តីសង្ខេបនៅការធ្វើវិសោធនកម្មនេះតាមរយៈនៅវ៉ិបសាយ www.nmcog.org ។

មានកិច្ចប្រជុំពីរដែលបានរៀបចំឡើងកាលពីពេលថ្មីៗនេះ។ ទីមួយ កិច្ចប្រជុំជាសាធារណៈដើម្បីទទួលយកនូវមតិយោបល់ពីសាធារណៈជនទៅលើពង្រៀងវិសោធនកម្ម ដែលនឹងប្រព្រឹត្តទៅនៅម៉ោង៥:៣០ ល្ងាច ខែមិនា នៅទីតាំងការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន ម៉ីដូល-សិច ( Northern Middlesex Council of Governments) ដែលមានអាស័យដ្ឋាន 40 Church Street, Suite 200 ក្រុងឡូវ៉ើល រដ្ឋម៉ាសាជូសេដ។ លោកអ្នកក៏អាចផ្តល់ជាមតិយោបល់តាមរយៈទូរស័ព្ទដោយខលទៅកាន់លេខ (978) 454-8021, ext. 121 រឺតាមរយៈអ៊ីម៉េល jhoward@nmcog.org ។ ប្រសិនបើចង់សរសេរជាលិខិត លោកអ្នកអាចផ្ញើរទៅកាន់អាស័យដ្ឋានខាងលើបាន។ ពេលវេលានៃការផ្តល់មតិយោបលជាសាធារណៈសម្រាប់វិសោធនកម្មគម្រោង TIP នេះ នឹងត្រូវបញ្ចប់នៅថ្ងៃទី ២០ ខែមិនា។ កិច្ចប្រជុំជាសាធារណៈទីពីរនឹងរៀបចំឡើងនៅម៉ោង ២:០០ រសៀល ថ្ងៃទី២៥ ខែមិនា នៅការិយាល័យ NMMPO នៅពេលដែលដំណើរការនៃការចូលរួមជាសាធារណៈរបស់អង្គភាព NMMPO ស្របទៅនឹងតំរូវការនៃការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន។

**កំណត់ចំណាំៈ** ទីកតាំងនៃការរៀបចំកិច្ចប្រជុំនេះ ងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិត និងចំណតឡានក្រុង។ អង្គភាព NMMPO មានទីតាំងសុវត្ថិភាពសម្រាប់ចំណតកង់ ដែលស្ថិតនៅជាន់ទី ២ ។NMMPO ក៏ផ្តល់ផងដែរនូវទីកន្លែងស្នាក់នៅដ៏សមរម្យ និង,រឺ ជំនួយផ្នែកភាសាដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ (មានដូចជាអ្នកបកប្រែជាភាសាអង់គ្លេស និងភាសាផ្សេងទៀត, បកប្រែភាសាដោយមើលរឺស្តាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៍បកប្រែជាសម្លេងសម្រាប់អ្នកគរថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀត) តាមដែលមាន ។ សម្រាប់ការចូលរួមរបស់លោកអ្នក និងជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ext 121 រឺអ៊ីម៉េលទៅកាន់ jhoward@nmcog.org ។ រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ។

## NOTICE OF PUBLIC MEETINGS AND COMMENT OPPORTUNITY: Draft Amendment to the NMMPO's FFY 2020-2024 Transportation Improvement Program

The Northern Middlesex Metropolitan Planning Organization (NMMPO) has released for public comment a draft amendment to the FFY 2020-2024 Transportation Improvement Program (TIP).The proposed TIP amendment involves programming funds for the Merrimack Riverwalk Extension Project in Lowell. A summary of the amendment can be found at www.nmcog.org.

There are two public meetings currently scheduled. One, a public meeting to receive comments on the draft amendment will be held on March 10, 5:30 PM, at the Northern Middlesex Council of Governments (NMCOG) offices, 40 Church Street, Suite 200, Lowell, MA. You may also submit comments by phone at (978) 454-8021, ext. 121, or by email: jhoward@nmcog.org. If preferred, comments may be mailed to the above address. The public comment period for the TIP amendment ends on March 20. The second public meeting is scheduled for March 25, 2:00 PM at NMCOG offices, when the NMMPO will meet to consider endorsement of the amendment. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

**Notice:** This meeting location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext. 121 or at jhoward@nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including sign language, CART or language translation or interpretation.

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

**ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មានសំបុត្រពេទ្យ*
- *មាសហ៊ែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសម៉ានីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ "ខេជីអេ"

## អវសាន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

ចុងឆ្នាំ២៩៩៥ សមាគមបានមកដល់ដំណាក់ការមួយដែលពិបាកនឹងស្តាឡើងវិញ ដោយសារអ្នកកាសែតចាប់ខ្លួនដោយរដ្ឋាភិបាលនឹងត្រូវគេសម្លាប់ដោយរកឃាដកឬមិនដែលឃើញកាន់តែកើនចំនួន ហើយការប្រទាញប្រទង់ផ្ទៃក្នុង ក៏ត្រូវបង្ហាញខ្លួនកាន់តែច្បាស់លាស់។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនត្រឹមតែកំចាត់សត្រូវរបស់លោក គឺទ្រង់នរោត្តម រណឬទ្ធិ តែប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវកំចាត់សមាគមអ្នកកាសែត ដែលកំពុងតែមានប្រជាប្រិយភាពជាមួយសហគមន៏អន្តរជាតិទៀតផង។ បន្ថែមពីលើនោះ លោកហ៊ុនសែនបានបង្កើតសមាគមសម្ព័ន្ធអ្នកកាសែតកម្ពុជាដឹកនាំដោយ ជុំ កាណាល់ នាខែមិថុនា ១៩៩៥ បានទាក់ទាញយកសមាជិកពីអង្គភាពរដ្ឋនឹងអង្គភាពគណបក្សប្រជាជនដើម្បីបំបាក់ KJA ។

ការប្រទាញប្រទង់ផ្ទៃក្នុងបណ្តាលមកពីបន្ទាប់ពីលោក ហ៊ុន សែន កំចាត់ទ្រង់នរោត្តម សេរីវុឌ្ឍ ឱ្យចេញពីគណបក្សហ្វ៊ុនស៊ិនប៉ិចប្រកបដោយជោគជ័យរួចហើយ, សូ ណារ៉ូ ជាអគ្គលេខាសមាគមមានការអាក់អន់ស្រពន់ចិត្តនឹង ពិន សំខុន ជាប្រធានខ្លួន យ៉ាងខ្លាំង ហើយថា "ពិន សំខុន មិនបានជួយខ្លួនក្នុងនាមជាអ្នកកាសែតដូចគ្នា"។ ពិន សំខុន បានឱ្យ សូណារ៉ូ យល់ថា "សូណារ៉ូ ពុំមែនជាអ្នករងគ្រោះនោះទេ ពីព្រោះមានរដ្ឋភិបាលជាអ្នកការពាររួចហើយ"។ ពិន សំខុន បានកោះប្រជុំប្រធានកាសែតឯករាជ្យនឹងមានវិជ្ជាជីវមាន ដឹខាបូឌា ដេលី នឹង ភ្នំពេញផូស ដើម្បីអានអត្ថបទកាសែត"គោកធ្លក"របស់សូណារ៉ូ ដែលបានចោទប្រកាន់ទ្រង់ សេរីវុឌ្ឍ ថា "ជាអ្នកប៉ុនប៉ងសម្លាប់លោក ហ៊ុន សែន" គេបាននាំគ្នាយល់ថា ជា"អត្ថបទ



គ្មានវិជ្ជាជីវៈ ផ្តល់ពិត័មានប្រកបដោយការខ្វះខាតមិនអាចយកជាការពិតបានឡើយ"ប៉ុន្តែលោក ហ៊ុន សែន នឹងតុលាការរបស់លោកមិនបានគិតដូច្នោះនោះទេ ។ ចាប់ពីពេលនោះមក សូ ណារ៉ូ ក៏បានក្លាយ ជាមនុស្សប្រឆាំងនឹង ពិន សំខុន នឹងសមាគមដែលថា "មិនបានការពារ សូណារ៉ូ" តែក៏មិនមានធ្វើសកម្មភាពអ្វី ដែលបណ្តាលឱ្យ សូ ណារ៉ូ រងគ្រោះដែរ។

ការបោះឆ្នោតចុងក្រោយមួយ នាថ្ងៃទី៥ ខែមករា ១៩៩៦ នាទិស្នាក់ការក្រោយវត្តលង្ការ ដែលមានទ្រង់ទ្រាយជានយោបាយរបស់គណបក្សប្រជាជន ដើម្បីរំលំអង្គការសារព័តិមានសេរីនៅកម្ពុជា។

សន្លឹកឆ្នោតនៃសមាជិកទាំង៣២អង្គភាពមានដំណាង២សម្លេងក្នុង១អង្គភាពទាំងអស់មានសម្លេង ៦៤, តែក្នុងនោះមានអង្គភាពកាសែត"ទឹយ"ជាភាសាវៀតណាមមិនបានចុលមកបោះឆ្នោតទេ ដោយនាយករបស់ពួកគេ បានត្រូវមេប៉ូលីស ហុក ឡុងឌី ចាប់ខ្លួនបញ្ជូនទៅវៀតណាម តាមបណ្តឹងរបស់សមាជិក KJA ម្នាក់ឈ្មោះ សូ ណារ៉ូ, ពេលនោះ ទាំងក្រសួងមហាផ្ទៃដំណាងក្នុងសមាគមដោយអង្គភាពសារព័តិមានក្រសួងមហាផ្ទៃវរសេនីយ ផៃ ស៊ីណាឬទ្ធ នឹង ទាំងក្រសួងពត័មានបានចេញបញ្ជាមិនឱ្យបោះឆ្នោតឱ្យ ពិន សំខុន ទេ។ បេក្ខភាពប្រធានសមាគមពេលនោះមាន ពិន សំខុន , តាត លីហុក , គីម វិមល់ ។ តាត លីហុក ជាសមាជិកគណបក្សប្រជាជនជាអនុប្រធានកាសែតដំធំបង្អស់របស់រដ្ឋនឹងគណបក្សប្រជាជនទំនងជាអ្នកដែលនឹងមកទទួលដំណែងជាប្រធានសមាគម, រីឯ គឹម វិមល ជានាយកកាសែតអប្សរ៉ារ៉ាម៉ា បូមានប្រជាប្រិយភាពទេ តែត្រូវបានបញ្ចុះបញ្ចូលដោយ សូ ណារ៉ូ ដើម្បីបំបែកឆ្នោត ពិន សំខុន, ជាមួយគ្នានោះមនុស្សដដែលក៏បានបញ្ចុះបញ្ចូល "ភាប្ញិទ្ធ ជានាយករងកាសែត ខ្មែរឯករាជ្យជាកាសែតរបស់ ពិន សំខុន ឱ្យបោះឆ្នោតប្រឆាំងនឹង ពិន សំខុន ទៀត ដែលគម្រោងនេះ ធ្វើឱ្យ សូ ណារ៉ូ សង្ឃឹមយ៉ាងមាំថា នឹងឱ្យជ័យជំនះដល់លោក ហ៊ុន សែន បានជាប្រាកដ។ ពេលបោះឆ្នោតមកដល់ សមាជិកបានមកគ្រប់ចំនួនុំ, ពិន សំខុន បានស្នើឱ្យ សូ ណារ៉ូ ទទួលដំណែងជាប្រធានគណកម្មការគ្រប់គ្រងបោះឆ្នោតសមាគម ដែលមានសមាជិកជាង៨0% មកពីអង្គភាពកាសែតដែលមាននិន្នាការជាគណបក្សប្រជាជន។

លទ្ធផលនៃការរាប់សន្លឹកឆ្នោតដោយ សូ ណារ៉ូ បាន តាត លិហុក ៣១សម្លេង, ពិន សំខុន បាន ៣១សម្លេងស្មើគ្នា, គីម វិមល បាន១សម្លេង ។ សមាជិកនៃអង្គប្រជុំបានមូលមតិគ្នាជាឯកច្ឆន្ទៈប្រកែកមិនឱ្យបន្តបោះឆ្នោតទៅជុំទី២ ហើយប្រកាសយកការដឹកនាំជា"សហប្រធាន"ដូចគ្នានឹងគំរូសហនាយករដ្ឋមន្ត្រីខ្មែរដែរ។

ការបោះឆ្នោតបានលទ្ធផលអវិជ្ជមានសម្រាប់គណបក្សប្រជាជន... ដោយសារការប៉ុនប៉ងដក ពិន សំខុន ចេញពីដំណែង"ប្រធានសមាគម" ដោយសន្លឹកឆ្នោតបានត្រូវបរាជ័យ, ប៉ុន្តែអង្គប្រជុំបែរជារីករាយនឹងលទ្ធផលរបៀបនេះទៅវិញ, មានតែ សូណារ៉ូ តែម្នាក់ប៉ុណ្ណោះ ក្នុងសមាគមដែលនៅតែខកចិត្តដដែល ។

នៅពេលជាមួយគ្នានោះ មិនត្រឹមតែសមាគមអ្នកសារពត័មានទេ ដែលរងការវាយប្រហារនោះ សូម្បីតែនាយករដ្ឋមន្ត្រីទី១ ទ្រង់ រណឬទ្ធិ ក៏រងការប្រទូសរាយដោយអាវុធច្រើនដង ជាមួយកម្លាំងលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ដែរ។

(នៅមានត)






**PRINT READERSHIP**

*50,000 Monthly / 600,000 Annually Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2020 PRINTING SCHEDULES

## EFFECTIVE FEBRUARY 1, 2020

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 7.5% Savings | 6 Months (12 Issues) 10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| | 5% Savings | 7.5% Savings | 10% Savings | |
| **Full** (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| **1/8** (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

**Your ad is also published in our online editions of the newspaper at khmerpostusa.com**




### MONTHLY DISTRIBUTION

*70+ Locations in Lowell, MA • 7,000 copies*
*25 Locations in Lynn & Revere, MA • 1,000 copies*
*25 Locations in Providence & Cranston, RI • 2,000 copies*
*Additional distribution online*

### *Khmer Post USA Distribution Locations Include:*

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

### CONTACT INFO

**27 Jackson Street • Unit 329 • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA